**ការជំទាស់របស់លោក អៀង សារី ទៅនឹងឯកសារនានាដែលបានស្នើឡើងដោយ ក.ស.ព នៅក្នុងឯកសារ E223/2/1 (E223/2/1.3)**

| No. | **លេខឯកសារ** | **ឯកសារ E9/31** | **ប្រភេទ** | **អ្នកនិពន្ធ/ អ្នកផ្តល់ឯកសារ** | **កាលបរិច្ឆេទ** | **ចំណងជើង** | **ការពិពណ៌នា** | **ចំណុចនៃការចោទប្រកាន់** | **ការជំទាស់** |
|---|---|---|---|---|---|---|---|---|---|
| **១** | ឯកសារ **D199/26.2.184** | ឯកសារ E9/31.18 (ឧបសម្ព័ន្ធ ១៨) លេខ ១១៧ | របាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ | AFP | ថ្ងៃទី២១ ខែមករា ឆ្នាំ១៩៧៦ | របាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ មានចំណងជើងថា ៖ “កម្ពុជា៖ ការជម្លៀសប្រជាជនដោយបង្ខំជាថ្មីម្តងទៀត ដែលបង្កគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស បើតាមកាសែត The New York Times” | វាយការណ៍ថា ចាប់តាំងពីចុងខែតុលា ឬដើមខែវិច្ឆិកា ឆ្នាំ១៩៧៥ ប្រជាជនកម្ពុជារាប់សែននាក់ត្រូវបានជម្លៀសដោយបង្ខំ ឆ្ពោះទៅកាន់ខេត្តបាត់ដំបង ហើយថា អ្នកដែលត្រូវបានគេជម្លៀសតាមរថភ្លើង ត្រូវបានគេញាត់ក្នុងទូរថភ្លើងដឹកទំនិញណែនក្តន់ ដូច “ត្រីខកំប៉ុង” ហើយថា ពួកគេជាច្រើនបានទទួលរងនូវជំងឺគ្រុនចាញ់ គ្រុនពោះវៀន អាសន្នរោគ រាគមួលជាដើម ហើយបានស្លាប់បាត់បង់ជីវិត។ | ការផ្លាស់ទីលំនៅប្រជាជន ពីភូមិភាគកណ្តាល (ឧត្តរចាស់) និរតី បស្ចិម និងបូព៌ា (ដំណាក់កាលទី២) [69: 262 ដល់ 282] | មេធាវីការពារក្តីទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចថា“សម្ភារៈមួយចំនួន ដូចជា របាយការណ៍ដែលមានការវិភាគ សៀវភៅ ភាពយន្តឯកសារ និងអត្ថបទដកស្រង់ចេញពីប្រព័ន្ធផ្សព្វផ្សាយ អាចមានការពាក់ព័ន្ធ ហើយនឹងត្រូវរាប់ចូលជាប្រភេទនៃឯកសារមួយផងដែរ” (ឯកសារ E185 កថាខណ្ឌ ២១(៥))។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីអះអាងថា អត្ថបទដកស្រង់ចេញពីប្រព័ន្ធផ្សព្វផ្សាយ មិនអាចទទួលយកថាមានលក្ខណៈត្រឹមត្រូវ ឬសត្យានុម័ត ដោយពុំបានសួរដេញដោលនោះឡើយ ជាពិសេសនៅពេលដែលអ្នកកាសែតអាចត្រូវបានរដ្ឋាភិបាលជួលឲ្យបង្ហាញនូវរបាយការណ៍ជាក់លាក់មួយអំពីព្រឹត្តការណ៍នានា ឬឲ្យបង្កើតនូវព័ត៌មានមិនពិត។ ពិតណាស់ វាស្ទើរតែមិនអាចវាយតម្លៃបានឡើយអំពីភាពត្រឹមត្រូវនៃអត្ថបទដកស្រង់ចេញពីប្រព័ន្ធផ្សព្វផ្សាយ ដោយគ្មាន ក្នុងកម្រិតអប្បបរមា ការបង្ហាញភ័ស្តុតាងពីអ្នកនិពន្ធនោះ។ វាមិនអាចទៅរួចឡើយក្នុងការបញ្ជាក់អំពីភាពគួរឲ្យជឿជាក់បាននៃរបាយការណ៍ដែលមានក្នុងអត្ថបទនោះ។<br><br>អត្ថបទនេះមានព័ត៌មាន និងសេចក្តីសន្និដ្ឋាន ដែលមិនបានផ្អែកទៅលើការអង្កេតផ្ទាល់អំពីព្រឹត្តិការណ៍ទាំងនោះឡើយ។ មិនមានរៀបរាប់បញ្ជាក់អំពីអ្នកនិពន្ធ។ ឯកសារនេះមិនគួរឲ្យជឿជាក់បាន និងមិនសមស្របក្នុងការបញ្ជាក់អង្គហេតុ ដែលឯកសារនេះចង់បញ្ជាក់ឡើយ ហើយឯកសារនេះមិនអាចទទួលយកបានឡើយ អនុលោមតាមវិធាន ៨៧(៣)(គ) នៃវិធានផ្ទៃក្នុង។ លើសពីនេះទៀត ដោយសារតែលោក អៀង សារី មិនបានទទួលនូវសិទ្ធិរបស់គាត់ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | អនុលោមតាមវិធាន ៨៤(១) នៃវិធានផ្ទៃក្នុង ដើម្បីតទល់ជាមួយនឹងអ្នកនិពន្ធអត្ថបទនេះ ឯកសារនេះក៏មិនអាចទទួលយកបានផងដែរ អនុលោមតាមវិធាន ៨៧(៣)(ឃ) នៃវិធានផ្ទៃក្នុង។ ប្រសិនបើឯកសារនេះត្រូវបានទទួលយក មេធាវីការពារក្ដី លើកឡើងថា ឯកសារនេះគួរតែមានទម្ងន់តិចតួចប៉ុណ្ណោះ ប្រសិនបើមាន លើកលែងតែខ្លឹមសារនៃឯកសារនេះអាចត្រូវបានពិនិត្យផ្ទៀងផ្ទាត់ ឬគាំទ្រ តាមរយៈសូចនាឯករាជ្យមួយ។ សម្រាប់ទឡ្ហីករណ៍បន្ថែមទៀត សូមមើល ការជំទាស់របស់លោក អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារជាក់លាក់មួយចំនួន ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **E114** កថាខណ្ឌ ១ (បទដ្ឋានក្នុងការទទួលយកភ័ស្ដុតាងជាឯកសារដែលមានចែងក្នុង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក) កថាខណ្ឌ ៧-៩ (ភាពអាចជឿជាក់បាន) កថាខណ្ឌ ១១ (ភាពពាក់ព័ន្ធ) កថាខណ្ឌ ១៨-១៩ (របាយការណ៍ អត្ថបទ និងឯកសារនានាដែលមិនបានបន្សល់ទុកពីសម័យនោះ)។ |
| **២** | ឯកសារ **D166/130** | ឯកសារ E9/31.20 (ឧបសម្ព័ន្ធ ២០) លេខ ៧៩ | របាយការណ៍ស្ដីពីការចាត់ឱ្យស៊ើបសួរជំនួស | អ.វ.ត.ក-ក.ស.ច.ស | ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ | របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស | រៀបរាប់អំពីការស្ដាប់ចម្លើយ ថេង ហ៊ុយ, ស៊ិន ស៊ិន, ឡាច គ្រី, វ៉ាន់ ម៉ៅ និង សោម រស់ ទាក់ទិននឹងការប្រព្រឹត្ត និងការជម្លៀសប្រជាជនវៀតណាមពីខេត្តព្រៃវែង។ | ការផ្លាស់ទីលំនៅប្រជាជន ពីភូមិភាគកណ្ដាល (ឧត្តរចាស់), និរតី, បស្ចិម និងបូព៌ា៖ ដំណាក់កាលទី២ [69:262 ដល់ 282], ការប្រព្រឹត្តលើជនជាតិវៀតណាម **[196: 791 ដល់ 841]** | ឯកសារនេះគឺជារបាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។ ឯកសារនេះមានសេចក្ដីសង្ខេបអំពីការស្ដាប់ចម្លើយសាក្សីនានា និងពិតជាមិនបានឆ្លុះបញ្ចាំងនូវការផ្ដល់ចម្លើយពិតត្រឹមត្រូវដែលសាក្សីអាចបានឆ្លើយតបទៅនឹងសំណួរដែលបានសួរពួកគាត់នោះឡើយ។ ដូច្នេះ ឯកសារនេះគួរត្រូវបានបដិសេធចោល អនុលោមតាមវិធាន ៨៧(៣)(គ) នៃវិធានផ្ទៃក្នុង ដោយសារតែឯកសារនេះមិនគួរឱ្យជឿជាក់បាន និងមិនសមស្របក្នុងការបញ្ជាក់អង្គហេតុ ដែលឯកសារនេះចង់បញ្ជាក់ឡើយ។ លើសពីនេះទៀត លោក អៀង សារី មិនត្រូវបានផ្ដល់នូវឱកាសដើម្បីតទល់ជាមួយនឹងសាក្សីទាំងនេះឡើយ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឯកសារនេះអាចទទួលយកបាន អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះគួរតែផ្ដល់នូវទម្ងន់តិចតួច ឬគួរកុំផ្ដល់នូវទម្ងន់ឡើយចំពោះចម្លើយរបស់សាក្សី |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | ដែលមាននៅក្នុងឯកសារនេះ។ យោងតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E96/7** កថាខណ្ឌ ២៤ ចម្លើយសាក្សីនៅក្នុងរបាយការណ៍នេះ មិនគួរត្រូវបានផ្ដល់នូវតម្លៃជាភស្ដុតាងឡើយ លើកលែងតែ ចម្លើយទាំងនេះ៖ មានចរិតលក្ខណៈត្រូតគ្នា, ទាក់ទិននឹងសារតារ, កន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើង ឬសក្ខីកម្មអំពីកម្រិតធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ, ជាការវិភាគមួយជាទូទៅ ឬជាស្ថិតិ ស្ដីពីសមាសភាគជាតិពន្ធុនៃប្រជាជន, ពាក់ព័ន្ធនឹងផលប៉ះពាល់ទៅលើជនរងគ្រោះ ឬមិនអាចដាក់ឲ្យស្ថិតនៅក្រោមការតទល់គ្នា ពីព្រោះសាក្សីផ្ដល់ចម្លើយនោះបានស្លាប់ ឬមិនអាចតាមរកឃើញ ឬមិនអាចមកផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់បាន។ សម្រាប់ទឡ្ហីករណ៍បន្ថែមទៀត សូមមើលចម្លើយតបរបស់លោក អៀង សារី ចំពោះសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឲ្យបើសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ **E96/3**។ ការជំទាស់របស់លោក អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារជាក់លាក់មួយចំនួន ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **E114** កថាខណ្ឌ ១ (បទដ្ឋាន ក្នុងការទទួលយកភស្ដុតាងជាឯកសារដែលមានចែងក្នុង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក) កថាខណ្ឌ ៧-៩ (ភាពអាចជឿជាក់បាន) កថាខណ្ឌ ១១ (ភាពពាក់ព័ន្ធ) កថាខណ្ឌ ១៨-១៩ (របាយការណ៍ អត្ថបទ និងឯកសារនានាដែលមិនបានបន្សល់ទុកពីសម័យនោះ)។ |